# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០២៤៧/២៣ ក.ប/ ស.ជ.ណ.ស.ប

## សេចក្តីជូនដំណឹង

## ស្តីពី

## ការស្នើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិមាត្រា១ នៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលមានតម្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤ ត្រូវដាក់សំណើសុំការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៤ ចាប់ពី**ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣** តាមរយៈគេហទំព័រ **www.fwcms.mlvt.gov.kh**។

ក្នុងករណី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន បានប្រើប្រាស់ហត្ថពលកម្មបរទេសដោយគ្មានលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស ល្មើសនឹងមាត្រា២៦៤ យោងមាត្រា៣៦៩ នៃច្បាប់ស្តីពីការងារ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីហុកសិបមួយថ្ងៃទៅកៅសិបថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីប្រាំមួយថ្ងៃទៅមួយខែ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហេង សួរ**

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ